# ស្តង់ដារគុណភាពអប្បបរមា សម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំ លើគ្រឹះស្ថានឧត្តមសិក្សា

១. បេសកកម្ម

២. រចនាសម្ព័ន្ធគ្រប់គ្រង ការគ្រប់គ្រង និងគំរោងផែនការ

៣. កម្មវិធីសិក្សា

៤. បុគ្គលិកសិក្សា

៥. និស្សិត និងសេវាសម្រាប់និស្សិត

៦. សេវាសិក្សា

៧. ទីតាំងសម្ភាររូបវ័ន្ត

៨. គម្រោងផែនការ និងការគ្រប់គ្រងថវិកា

៩. ការផ្សព្វផ្សាយព័ត៌មាន

២០១០

# មាតិកា

**ចំណងជើង** | **ទំព័រ**


សេចក្តីផ្តើម ................................................................ ០១

ស្តង់ដារទី១ : បេសកកម្ម................................................. ០៣

ស្តង់ដារទី២ : រចនាសម្ព័ន្ធគ្រប់ ការគ្រប់គ្រង និងគំរោងផែនការ........ ០៤

ស្តង់ដារទី៣ : កម្មវិធីសិក្សា................................................ ០៩

ស្តង់ដារទី៤ : បុគ្គលិកសិក្សា................................................ ១៣

ស្តង់ដារទី៥ : និស្សិត និង សេវាសម្រាប់និស្សិត............................ ១៦

ស្តង់ដារទី៦ : សេវាសិក្សា................................................. ១៩

ស្តង់ដារទី៧ : ទីតាំងសម្ភាររូបវ័ន្ត.......................................... ២២

ស្តង់ដារទី៨ : គម្រោងផែនការ និងការគ្រប់គ្រងថវិកា.................. ២៤

ស្តង់ដារទី៩ : ការផ្សព្វផ្សាយព័តិមាន........................................ ២៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការ
ួលស្គាល់គុណភាពអប់រំនៃកម្ពុជា
ខ: ០២ /០៩ គ.ទ.ក ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ស្តង់ដារគុណភាពអប្បបរមាសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា

## ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការ កែសម្រួល មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការ ទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៣៥ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- យោងតាមលទ្ធផលអង្គប្រជុំគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៨

## សម្រេច

**ប្រការ១.~**

សេចក្តីសម្រេចនេះ មានគោលបំណងកំណត់អំពីស្តង់ដារគុណភាពអប្បបរមាសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ដើម្បីវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំដល់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.~**

ស្តង់ដារគុណភាពអប្បបរមាសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា មានខ្លឹមសារទាំងស្រុងដូចតទៅ :

# សេចក្តីផ្តើម

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក.) ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យ លេខ នស/ រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សាដើម្បីគ្រប់គ្រងដំណើរការនៃការធានានិងលើកកំពស់គុណភាពអប់រំឧត្តមសិក្សានៅកម្ពុជា ឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ ។ អនុវត្តតាមស្មារតីនៃព្រះរាជក្រឹត្យនេះ នឹងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងចតុកោណទី៤ មុំទី១ ស្តីពីការពង្រឹងគុណភាពវិស័យអប់រំ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គ.ទ.ក. បានបង្កើតស្តង់ដារគុណភាពអប្បបរមាសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សាដែលជាឧបករណ៍គតិយុត្តិចាំបាច់មួយសំរាប់វាយតម្លៃដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សាទាំងមូល និងលើកកម្ពស់គុណភាពអប់រំឧត្តមសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការវាយតម្លៃសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំមានគោលបំណងដើម្បីបញ្ជាក់ថា គ្រឹះស្ថានឧត្តមសិក្សាណាមួយមានគុណភាពអប់រំក្នុងកំរិតណាមួយដែលជាព័ត៌មានសម្រាប់និស្សិត មាតាបិតា និងសហគមន៍ផ្តល់ជំនួយនានាក្នុងការសម្រេចចិត្តជ្រើសរើសគ្រឹះស្ថានឧត្តមសិក្សា ដើម្បីចូលរៀន និងផ្តល់ជំនួយ និងជាព័ត៌មានសម្រាប់និយោជកក្នុងការជ្រើសរើសនិយោជិតបំរើការងារក្នុងអង្គភាពរបស់ខ្លួន និងមានគោលបំណងដើម្បីផ្តល់អនុសាសន៍លើការពង្រឹងគុណភាពអប់រំដល់គ្រឹះស្ថានឧត្តមសិក្សា ក្រសួងឬស្ថាប័នពាក់ព័ន្ធ និងរាជរដ្ឋាភិបាល ក្នុងការរៀបចំគោលនយោបាយកំណែទំរង់ប្រព័ន្ធអប់រំឧត្តមសិក្សា ។

ស្តង់ដារគុណភាពអប្បបរមា រួមមានចំនួន ៩ស្តង់ដារ គឺ ÷

១. បេសកកម្ម

២. រចនាសម្ព័ន្ធគ្រប់គ្រង ការគ្រប់គ្រង និងគម្រោងផែនការ

៣. កម្មវិធីសិក្សា

៤. បុគ្គលិកសិក្សា
៥. និស្សិតនិងសេវាសម្រាប់និស្សិត
៦. សេវាសិក្សា
៧. ទីតាំង សម្ភារ រូបវ័ន្ត
៨. គម្រោងផែនការ និងការគ្រប់គ្រងថវិកា
៩. ការផ្សព្វផ្សាយព័ត៌មាន ។

ស្តង់ដារគុណភាពអប្បបរមានេះ ត្រូវបានរៀបចំឡើងចាប់ពីចុងឆ្នាំ២០០៣ ដោយយោងតាមស្មារតីនៃ ព្រះរាជក្រឹត្យ លេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេងៗទៀត ។ បន្ថែមពីនេះ ស្តង់ដារនេះត្រូវបានដាក់ឱ្យអ្នកជំនាញការបរទេស និងរៀបចំសិក្ខាសាលាផ្តល់យោបល់ជាបន្តបន្ទាប់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេស ពីក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សាទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ស្តង់ដារគុណភាពនេះឆ្លើយតបនឹងសេចក្តីត្រូវការ និងបរិបទនៃប្រទេសកម្ពុជា ទាំងទិដ្ឋភាពច្បាប់ សង្គម សេដ្ឋកិច្ច និងអាចអនុវត្តបានគ្រប់គ្រឹះស្ថានឧត្តមសិក្សា ហើយក៏មិនឃ្លាតឆ្ងាយពីស្តង់ដារនៃបណ្តាប្រទេសមួយចំនួនក្នុងតំបន់ និងអន្តរជាតិ ។

ស្តង់ដារគុណភាពនេះ មានវិសាលភាពអនុវត្ត លើគ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ទាំងសាធារណៈ និងឯកជន ក្នុងព្រះរាជាណាចក្រកម្ពុជា ។

# ស្តង់ដារទី១ : បេសកកម្ម

បេសកកម្ម របស់គ្រឹះស្ថានអប់រំឧត្តមសិក្សាកំណត់អំពីលក្ខណៈរបស់គ្រឹះស្ថានឧត្តមសិក្សា អំពីការបែងចែកប្រភេទ នៃគ្រឹះស្ថានឧត្តមសិក្សា អំពីសកម្មភាពអប់រំ និងតួនាទីរបស់គ្រឹះស្ថានឧត្តមសិក្សាក្នុងវិស័យអប់រំឧត្តមសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តោតការយកចិត្តទុកដាក់លើកម្រិតនៃការធានាសម្រេចបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សាស្របតាមធនធានដែលគ្រឹះស្ថានឧត្តមសិក្សាមាន ។ គោលបំណងចម្បងនៃការវាយតម្លៃ គឺសំដៅស្វែងយល់និងវិភាគអំពីភាពច្បាស់លាស់ ភាពសមស្រប និងភាពត្រឹមត្រូវនៃបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សាដែលបានផ្សព្វផ្សាយជាសាធារណៈ ។ ដើម្បីសម្រេចបានស្តង់ដារនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវបំពេញសូចនាករដូចខាងក្រោម ÷

**សូចនាករ**

១. ភាពច្បាស់លាស់នៃបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា ÷
   - ក. បេសកកម្ម ត្រូវរួមចំណែកការពារផលប្រយោជន៍ និងអភិវឌ្ឍប្រទេសជាតិ
   - ខ. បេសកកម្ម ត្រូវកំណត់អោយសមស្របតាមប្រភេទនៃគ្រឹះស្ថានឧត្តមសិក្សា និងធនធានរបស់គ្រឹះស្ថាន
   - គ. បេសកកម្ម ត្រូវមានអំណះអំណាងច្បាស់លាស់ដើម្បីធានាអោយមានប្រសិទ្ធភាពក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពដល់អ្នកសិក្សា

២. គ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្សព្វផ្សាយបេសកកម្មដល់សមាជិកនៃគ្រឹះស្ថាន និងភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ

៣. គ្រឹះស្ថានឧត្តមសិក្សា ត្រូវពិនិត្យ វិភាគ និងកែលំអបេសកកម្ម ក្នុងពេលវេលាកំណត់ណាមួយច្បាស់លាស់

៤. គ្រឹះស្ថានឧត្តមសិក្សាត្រូវជូនដំណឹងដល់សមាជិកនៃគ្រឹះស្ថានឧត្តមសិក្សា និងភាគីពាក់ព័ន្ធអំពីលទ្ធផលទទួលបានពីការពិនិត្យវាយតម្លៃ និងកែលំអនេះ ។

## ស្តង់ដារទី២ ៖ រចនាសម្ព័ន្ធគ្រប់គ្រង ការគ្រប់គ្រង និង គំរោងផែនការ

គ្រឹះស្ថានឧត្តមសិក្សាត្រូវមានប្រព័ន្ធអភិបាលកិច្ចដែលជួយធានាសម្រេចបេសកកម្មរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាល និងប្រធានប្រតិបត្តិមានតួនាទីស្នូលក្នុងការកំណត់គោលដៅអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា និង កំណត់បញ្ហាអាទិភាពដែលត្រូវដោះស្រាយ និងមានតួនាទីសំខាន់ក្នុងការតាក់តែងបង្កើតផែនការដែលងាយស្រួលអនុវត្ត។

បុគ្គលិករដ្ឋបាលមានតួនាទីសំខាន់ទ្រទ្រង់ដល់ដំណើរការបង្រៀន និងរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សា។ ដើម្បីសម្របសម្រួលដល់ការបំពេញតួនាទីនេះអោយកាន់តែមានប្រសិទ្ធភាព និងដើម្បីធានាអោយសម្រេចបានលទ្ធផលល្អ គ្រឹះស្ថានឧត្តមសិក្សាចាំបាច់ត្រូវមានគោលនយោបាយអភិបាលកិច្ច និងរដ្ឋបាលច្បាស់លាស់ ហើយអាចអនុវត្តបាន។ ដើម្បីសម្រេចបានស្តង់ដារនេះ គ្រឹះស្ថានឧត្តមសិក្សា ត្រូវបំពេញសូចនាករដូចខាងក្រោម ÷

**សូចនាករ**

១. គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង គ្រឹះស្ថានឧត្តមសិក្សាដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ÷

ការបង្កើត ការកំណត់តួនាទីភារកិច្ច ការតែងតាំងក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ ឬ នាយករបស់គ្រឹះស្ថាន ឧត្តមសិក្សាសាធារណៈ ត្រូវអនុវត្តស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល ឬ បទប្បញ្ញត្តិជាធរមានផ្សេងៗទៀត។

ការបង្កើត ការកំណត់តួនាទីភារកិច្ច ការតែតាំងក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ ឬ នាយក របស់គ្រឹះស្ថានឧត្តមសិក្សាដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុវត្តស្របតាមព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ បទបញ្ញត្តិជាធរមានផ្សេងៗទៀត។

២. គ្រឹះស្ថានឧត្តមសិក្សាឯកជន ៖

២.១. ក្រុមប្រឹក្សាភិបាលត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

ក. សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានសមាសភាពមកពីម្ចាស់ភាគហ៊ុនឬតំណាង តំណាងបុគ្គលិកឬ សាស្ត្រាចារ្យ ឥស្សរជនដែលមានចំណេះដឹងក៏រិតឧត្តមសិក្សា និងមានបទពិសោធក្នុងការគ្រប់គ្រងយ៉ាង តិច៥ឆ្នាំ និង/ឬ មកពី វិស័យពាក់ព័ន្ធ

ខ. ត្រូវមានដំណើរការជ្រើសរើសនិងជ្រើសតាំងក្រុមប្រឹក្សាភិបាល ប្រកបដោយតម្លាភាព

គ. ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកចាប់ពី៥រូបឡើងទៅ

ឃ. ត្រូវមានបទបញ្ជាផ្ទៃក្នុង ឬលក្ខន្តិកៈសម្រាប់ក្រុមប្រឹក្សាភិបាល

ង. ក្រុមប្រឹក្សាភិបាលមានអាណត្តិ៣ឆ្នាំ ។

២.២. តួនាទីភារកិច្ចសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាល ៖

ក. កំណត់អាណត្តិ និង លក្ខខណ្ឌសម្រាប់ការតែងតាំងសាកលវិទ្យាធិការ ឬ នាយក

ខ. ពិនិត្យ និងផ្ដល់ការយល់ព្រមលើផែនការហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ឧត្តមសិក្សា និងកំណត់ថ្លៃសិក្សា

គ. ផ្ដល់ការយល់ព្រមលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីសិក្សាព្រមទាំងផ្ដល់ការយល់ព្រមលើគោលនយោបាយ និងនីតិវិធីសវនកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា

ឃ. ធានាអោយមានការអនុវត្តគោលនយោបាយផែនការយុទ្ធសាស្ត្រ និងកម្មវិធីបណ្ដុះបណ្ដាលរបស់គ្រឹះស្ថានឧត្តមសិក្សាប្រកបដោយប្រសិទ្ធភាព

ង. ពិនិត្យនិងផ្ដល់ការយល់ព្រមលើការផ្លាស់ប្ដូរគោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងកម្មវិធីបណ្ដុះបណ្ដាលរបស់គ្រឹះស្ថានឧត្តមសិក្សា

ច. ជ្រើសរើស តែងតាំង ផ្លាស់ប្តូរ និងដកហូតសាកលវិទ្យាធិការ/នាយក។ តែងតាំង ផ្លាស់ប្តូរ សាកលវិទ្យាធិការរង/នាយករង និងព្រឹទ្ធបុរសតាមការស្នើសុំរបស់សាកលវិទ្យាធិការ ឬ នាយក

ឆ. ធានាចំនួន ប្រភេទ និងកម្រិតនៃសញ្ញាបត្រដែលផ្តល់ដោយគ្រឹះស្ថានឧត្តមសិក្សាមានគុណភាព និងមានសង្គតិភាពជាមួយគោលបំណងរបស់គ្រឹះស្ថានឧត្តមសិក្សា

ជ. ផ្តល់ការយល់ព្រមលើរចនាសម្ព័ន្ធបណ្តុះបណ្តាល និងរចនាសម្ព័ន្ធរដ្ឋបាលដើម្បីធានាសម្រេចបេសកកម្ម និងគោលដៅរបស់គ្រឹះស្ថានឧត្តមសិក្សា

ឈ. ចូលរួមក្នុងដំណើរការនៃការធានាគុណភាពអប់រំ និងការទទួលស្គាល់គុណភាពអប់រំ។

២.៣. សាកលវិទ្យាធិការ/នាយក ÷

សាកលវិទ្យាធិការ/នាយកគ្រឹះស្ថានឧត្តមសិក្សាត្រូវបាន ជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សាភិបាល។

២.៤. តួនាទី និងភារកិច្ចសំខាន់ៗរបស់សាកលវិទ្យាធិការ/នាយកមានដូចខាងក្រោម ÷

ក. ទទួលខុសត្រូវលើការងារសិក្សាធិការ ការងារគ្រប់គ្រងរដ្ឋបាល សកម្មភាពផ្សេងៗ និងអនុវត្តគោលនយោបាយដែលអនុម័តដោយក្រុមប្រឹក្សាភិបាល

ខ. ផ្តួចផ្តើម នឹងដឹកនាំរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា

គ. ធានាឱ្យមានការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សា

ឃ. ទទួលខុសត្រូវដឹកនាំការងារគ្រប់គ្រងទូទៅប្រចាំថ្ងៃរបស់គ្រឹះស្ថានឧត្តមសិក្សា

ង. ស្នើសុំ តែងតាំង ផ្លាស់ប្តូរ សាកលវិទ្យាធិការរង និងព្រឹទ្ធបុរស

ច. ជ្រើសរើស តែងតាំង ដកហូត និងផ្លាស់ប្តូរមន្ត្រីថ្នាក់ក្រោមតំណែងព្រឹទ្ធបុរស

ឆ. ធ្វើរបាយការណ៍ ពីសកម្មភាពការងាររបស់ខ្លួនយ៉ាងទៀង ទាត់ជូនក្រុមប្រឹក្សាភិបាល

ជ. ផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំជាសាធារណៈ

៣. រចនាសម្ព័ន្ធគ្រប់គ្រង និងប្រព័ន្ធរដ្ឋបាលរបស់គ្រឹះស្ថានឧត្តមសិក្សា ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងរួមនិងដោយ ឡែកតាមមហាវិទ្យាល័យ ដោយតែងតាំងមន្ត្រីមានសមត្ថភាព កំណត់តួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រី និងមុខងារ របស់គណៈកម្មាធិការ និង/ឬ ក្រុមប្រឹក្សានានា

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានការិយាល័យ ឬផ្នែកមួយចំនួនដើម្បី ធានាដល់ដំណើរការការងារដូចខាងក្រោម ÷

- រដ្ឋបាល និងបុគ្គលិក
- ផែនការ និងហិរញ្ញកិច្ច
- ការសិក្សា និងកិច្ចការនិស្សិត
- ការស្រាវជ្រាវ និងផ្សព្វផ្សាយ
- សហប្រតិបត្តិការ
- ការងារផ្សេងទៀតតាមការចាំបាច់របស់គ្រឹះស្ថានឧត្តមសិក្សា

៤. ការជ្រើសរើសមន្ត្រី និងការបែងចែកធនធាន

ក. ការជ្រើសរើសមន្ត្រីគ្រប់គ្រង និង មន្ត្រីនានាត្រូវឆ្លុះបញ្ចាំងពីគោល បំណងរបស់គ្រឹះស្ថាន និងទំហំការងារ

ខ. ការគ្រប់គ្រង និងបែងចែកធនធានត្រូវធ្វើឡើងអោយមានសង្គតិ ភាពជាមួយអាទិភាពរបស់គ្រឹះស្ថាន ។

៥. ផែនការ និងការវាយតម្លៃ ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានផែនការយុទ្ធសាស្ត្រច្បាស់លាស់ ដែល ឆ្លើយតបទៅនឹងតម្រូវការ និង ស្ថានភាពប្រែប្រួលនៃវិស័យ អប់រំឧត្តមសិក្សា ហើយស្របទៅនឹងបេសកកម្ម និងធនធានរបស់ គ្រឹះស្ថានឧត្តមសិក្សា

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវធ្វើផែនការបន្តមួយសម្រាប់ធានាលើក កម្ពស់គុណភាពផ្ទៃក្នុងរបស់គ្រឹះស្ថាន

គ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានផែនការបណ្តុះបណ្តាល និង ផែនការគ្រប់គ្រងសម្ភាររូបវ័ន្តដែលមានសង្គតិភាពជាមួយបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា

ឃ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានផែនការហិរញ្ញវត្ថុរយៈពេលវែង និងគម្រោងថវិកាប្រចាំឆ្នាំ និងត្រូវធ្វើសវនកម្មតាមកាលកំណត់

ង. គ្រឹះស្ថានឧត្តមសិក្សាត្រូវវាយតម្លៃលើការអនុវត្តផែនការរបស់ខ្លួនជាប្រចាំដើម្បីវាស់ស្ទង់ពីការសម្រេចបាននូវបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា។

៦. គុណវុឌ្ឍិរបស់មន្ត្រីគ្រប់គ្រង ÷

ក. សាកលវិទ្យាធិការ ឬនាយកនៃគ្រឹះស្ថានឧត្តមសិក្សាត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ ឬ សញ្ញាបត្រមានតម្លៃស្មើ និងមានបទពិសោធន៍យ៉ាងតិច៥ឆ្នាំ ក្នុងផ្នែកអប់រំឧត្តមសិក្សា ឬផ្នែកគ្រប់គ្រង

ខ. សាកលវិទ្យាធិការរង ឬ នាយករង នៃគ្រឹះស្ថានឧត្តមសិក្សាត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រមានតម្លៃស្មើ និងមានបទពិសោធន៏យ៉ាងតិច៥ឆ្នាំ ក្នុងផ្នែកអប់រំឧត្តមសិក្សា ឬ ផ្នែកគ្រប់គ្រង លើកលែងតែសាកលវិទ្យាធិការរង ឬ នាយករងទទួលបន្ទុកសិក្សាដែលត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាប័ត្រមានតម្លៃស្មើ និងមានបទពិសោធយ៉ាងតិច៥ឆ្នាំក្នុងផ្នែកអប់រំឧត្តមសិក្សា ឬ ផ្នែកគ្រប់គ្រង

គ. ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងគ្រឹះស្ថានឧត្តមសិក្សាដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានគុណវុឌ្ឍិស្របនឹងបទដ្ឋានច្បាប់ជាធរមានរបស់រាជរដ្ឋាភិបាលកម្ពុជា

ឃ. មន្ត្រីគ្រប់គ្រងផ្នែកសិក្សាធិការ ដូចជាព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងប្រធានដេប៉ាតឺម៉ង់ ត្រូវមានសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រមានតម្លៃស្មើ និងត្រូវមានបទពិសោធបង្រៀន នៅឧត្តមសិក្សា។

# ស្តង់ដារទី៣ : កម្មវិធីសិក្សា

ការសម្រេចបាន និងការរក្សាបាននូវកម្មវិធីសិក្សាប្រកបដោយគុណភាពខ្ពស់ គឺជាការទទួលខុសត្រូវបឋមរបស់គ្រឹះស្ថានឧត្តមសិក្សាដែលមានគុណភាព។ ហេតុនេះហើយការវាយតម្លៃ និង ការអភិវឌ្ឍលើកម្មវិធីសិក្សា គឺជាកិច្ចការដែលត្រូវធ្វើជានិរន្តរ៍។ ដោយលក្ខខណ្ឌ និងតម្រូវការតែងមានការផ្លាស់ប្តូរ គ្រឹះស្ថានឧត្តមសិក្សាត្រូវកំណត់ឡើងវិញ អំពីកម្មវិធីសិក្សាដែលអាចធានាលើកកម្ពស់គុណភាពអប់រំ។ ដើម្បីសម្រេចបានជោគជ័យលើការងារនេះ ការរៀបចំផែនការសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាត្រូវពឹងផ្អែកលើការវាយតម្លៃជាទៀងទាត់លើបេសកកម្មរបស់គ្រឹះស្ថាន រួមទាំងតម្រូវការទីផ្សារការងារ តម្រូវការរបស់និស្សិត និងផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍជាតិ។ ដើម្បីសម្រេចបានស្តង់ដារនេះ គ្រឹះស្ថានឧត្តមសិក្សា ត្រូវបំពេញសូចនាករដូចខាងក្រោម÷

**សូចនាករ**

១. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា និងក្រុមប្រឹក្សាផ្តល់យោបល់ដែលមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវរៀបចំ និងអភិវឌ្ឍកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពឆ្លើយតបទៅនឹងបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា ។

២. ខ្លឹមសារ និងការរៀបចំកម្មវិធីសិក្សា÷

ក. កម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សាត្រូវស្របទៅនឹងគោលនយោបាយជាតិ និងតម្រូវការសង្គម

ខ. កម្មវិធីសិក្សាត្រូវស្របនឹងបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា

គ. កម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំឱ្យស្របតាមសេចក្តីសម្រេច ស្តីពីការអនុវត្តកម្មវិធីសិក្សា តាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីតលេខ ០៤/០៤ គ.ទ.ក.សសវ. ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤

ឃ. កម្មវិធីសិក្សាត្រូវផ្សាភ្ជាប់ទៅនឹងការសិក្សាស្រាវជ្រាវដែលមានប្រយោជន៍ដល់សង្គមជាតិ

ង. កម្មវិធីសិក្សាត្រូវមានគោលបំណង ការពិពណ៌នា និងប្លង់រួមនៃមុខវិជ្ជានៅក្នុងមហាវិទ្យាល័យនីមួយៗ ច្បាស់លាស់ និងត្រូវបោះពុម្ពផ្សព្វផ្សាយជាផ្លូវការ

ច. មុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាត្រូវផ្អែកលើសៀវភៅគោលដែលមានឯកសារពិគ្រោះផ្សេងៗ

ឆ. មុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាត្រូវមានចែងអំពីគោលបំណង នៃ-មុខវិជ្ជា ចំនួនក្រេឌីត ការពិពណ៌នាអំពីមុខវិជ្ជា ខ្លឹមសារមេរៀន ប្រព័ន្ធនៃការផ្តល់ពិន្ទុ និងវិធីសាស្ត្រនៃការបង្រៀន។

៣. ដំណើរការនៃការសិក្សាតាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវបង្កើតយន្តការបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីតមួយដែលអនុញ្ញាតដល់ការសិក្សា មិនពេញម៉ោង ឬការបញ្ចូលគ្នារវាងនិស្សិតសិក្សាមិនពេញម៉ោង និង និស្សិតសិក្សាពេញម៉ោង

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគោលនយោបាយ ស្តីពីការផ្ទេរក្រេឌីតនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ឬ កិច្ចព្រមព្រៀង ស្តីពីការផ្ទេរក្រេឌីតរវាងគ្រឹះស្ថានឧត្តមសិក្សាផ្សេងៗដែលមានការទទួលស្គាល់គុណភាពអប់រំត្រឹមត្រូវ ដោយផ្អែកតាមតម្រូវការនៃកម្មវិធីសិក្សានីមួយៗ

គ. ការរៀបចំក្រេឌីតសម្រាប់មុខវិជ្ជា វគ្គសិក្សា និងការផ្ទេរក្រេឌីត ត្រូវអនុលោមតាមសេចក្តីសំរេចលេខ ០៤/០៤ គ.ទ.ក សសរ ស្តីពីការសិក្សាតាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីតចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ។

៤. ប្រសិទ្ធភាពនៃការសិក្សា និងការបង្រៀន÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តល់តម្លៃ និងលើកទឹកចិត្តចំពោះការបង្រៀន និងការសិក្សាល្អរបស់គ្រូបង្រៀន និងនិស្សិត

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវបង្កើតបរិយាកាសសិក្សាល្អដើម្បីបង្កើន ប្រសិទ្ធភាពដល់ការបង្រៀន និងការសិក្សា

គ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានសេវាសិក្សាដែលគាំទ្រដល់ការសិក្សា និងការបង្រៀនប្រកបដោយប្រសិទ្ធភាព

ឃ. គ្រឹះស្ថានឧត្តមសិក្សាត្រូវបោះពុម្ពខិត្តប័ណ្ណសិក្សានៃជំនាញនីមួយៗ និងត្រូវផ្សព្វផ្សាយតាមរយៈគេហទំព័រ និងមធ្យោបាយផ្សេងៗ ។

៥. ការវាយតម្លៃការសិក្សារបស់និស្សិត ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវកំណត់ឱ្យបានច្បាស់លាស់ក្នុងកម្មវិធី បណ្តុះបណ្តាលនីមួយៗនូវវិធីសាស្ត្រនៃការវាយតម្លៃលទ្ធផលសិក្សា របស់និស្សិត ហើយត្រូវធ្វើការវាយតម្លៃប្រកបដោយតម្លាភាព និង ប្រសិទ្ធភាព

ខ. ការវាយតម្លៃការសិក្សារបស់និស្សិតត្រូវធ្វើឡើងតាមរយៈវិធីសាស្ត្រ ផ្សេងៗដោយផ្តល់ឱកាសឱ្យនិស្សិតមានអារម្មណ៍ទទួលបានជោគ ជ័យក្នុងការសិក្សាជាជាងការផ្តោតតែទៅលើការប្រលងបញ្ចប់ ។

៦. ការសិក្សាស្រាវជ្រាវ ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគណៈកម្មការសិក្សាស្រាវជ្រាវ ឬ គណៈកម្មការសម្របសម្រួលការងារសិក្សាស្រាវជ្រាវ ឬ មជ្ឈ មណ្ឌលស្រាវជ្រាវ

ខ. ធនធាន និងធនធានរូបវ័ន្តត្រូវមានការបែងចែកក្នុងទិសដៅគាំទ្រ ដល់គណៈកម្មការសិក្សាស្រាវជ្រាវ ឬ គណៈកម្មការសម្របសម្រួល ការងារសិក្សាស្រាវជ្រាវ ឬ មជ្ឈមណ្ឌលស្រាវជ្រាវរបស់គ្រឹះស្ថាន ឧត្តមសិក្សា

គ. គ្រឹះស្ថានឧត្តមសិក្សាត្រូវបង្កើតគោលការណ៍ និងការអនុវត្តការ ស្រាវជ្រាវ និងកំណត់ផែនការស្រាវជ្រាវ ដើម្បីលើកទឹកចិត្តដល់ ការងារស្រាវជ្រាវក្នុងគ្រឹះស្ថាន ។

៧. គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំបង្កើតប្រព័ន្ធធានាគុណភាពផ្ទៃក្នុងដែលមានគោលការណ៍ណែនាំ និងមាននីតិវិធីច្បាស់លាស់សម្រាប់ការអនុវត្តប្រព័ន្ធធានាគុណភាពផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សា។ គោលការណ៍ណែនាំទាំងនេះ ត្រូវស្របជាមួយនឹងគោលការណ៍នានារបស់ក្រសួងអប់រំ យុវជន និងកីឡា និង គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

៨. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានប្រព័ន្ធគ្រប់គ្រងឯកសារ នឹងថែរក្សាឯកសារសិក្សា ឯកសាររបស់និស្សិត និងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវអោយបានត្រឹមត្រូវ។

៩. ការបង្កើត និងការពិនិត្យឡើងវិញលើកម្មវិធីសិក្សា÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវធ្វើការវាយតម្លៃអំពីតម្រូវការរបស់និស្សិត និងទីផ្សារការងារសម្រាប់រៀបចំកម្មវិធីបណ្តុះបណ្តាលថ្មី និងកម្មវិធីសិក្សាថ្មី

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំអោយមានការពិគ្រោះយោបល់ និងការចូលរួមពីសំណាក់សមាជិករបស់គ្រឹះស្ថានឧត្តមសិក្សា វិស័យពាក់ព័ន្ធ និងនិយោជកក្នុងការបង្កើតកម្មវិធីសិក្សាថ្មី

គ. ការរៀបចំផែនការពិនិត្យឡើងវិញ និងការកែលំអកម្មវិធីសិក្សា ត្រូវផ្អែកលើការវាយតម្លៃ និងត្រូវផ្សារភ្ជាប់ នឹងតម្រូវការនៃមុខ ជំនាញ និងមានការចូលរួមពីសមាជិកគ្រឹះស្ថានឧត្តមសិក្សា និង ភាគីពាក់ព័ន្ធ

ឃ. គ្រឹះស្ថានឧត្តមសិក្សាត្រូវពិនិត្យ និងកែលំអយ៉ាងទៀងទាត់លើកម្មវិធីសិក្សា និងជំនាញឯកទេស ដែលគ្រឹះស្ថានបណ្តុះបណ្តាលដោយអនុវត្តតាមនីតិវិធីជាក់លាក់

ង. គ្រឹះស្ថានឧត្តមសិក្សាត្រូវស្រាវជ្រាវអំពីលទ្ធផល និងភាពជោគជ័យរបស់និស្សិតដែលបានបណ្តុះបណ្តាលក្នុងការទទួលបានការងារធ្វើ។

# ស្តង់ដារទី៤ ៖ បុគ្គលិកសិក្សា

ការជ្រើសរើស ការជួល ការរក្សា និងការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកសិក្សាជាកិច្ចការដ៏ចាំបាច់របស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ។ បុគ្គលិកសិក្សាមានភារកិច្ចក្នុងការចូលរួមដើម្បីធានាសម្រេចគោលដៅនៃកម្មវិធីសិក្សានិងលើកកម្ពស់គុណភាពអប់រំ។ ដើម្បីសម្រេចភារកិច្ចរបស់ខ្លួន បុគ្គលិកសិក្សាត្រូវមានឯករាជ្យភាពក្នុងកិច្ចការបង្រៀន និងមានសិទ្ធិចូលរួមក្នុង ដំណើរការសម្រេចចិត្តដែលមានឥទ្ធិពលលើកម្មវិធីអប់រំរបស់គ្រឹះស្ថានឧត្តមសិក្សា។ ដើម្បីសម្រេចបានស្តង់ដារនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវបំពេញសូចនាករដូចខាងក្រោម÷

**សូចនាករ**

១. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកសិក្សា÷

ក. បុគ្គលិកសិក្សាត្រូវមានតួនាទីក្នុងការអនុវត្តកម្មវិធីសិក្សា ដើម្បីធានាឱ្យមានគុណភាព និងលើកកម្ពស់កិត្យានុភាពរបស់គ្រឹះស្ថានឧត្តមសិក្សា ⁄

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តល់ឱកាសដល់បុគ្គលិកសិក្សាចូលរួមក្នុងដំណើរការសម្រេចចិត្ត ដែលមានឥទ្ធិពលលើកម្មវិធីសិក្សា

គ. ត្រូវមានការពិព័ណ៌នាភារកិច្ចទទួលខុសត្រូវច្បាស់លាស់សម្រាប់បុគ្គលិកសិក្សាស្របតាមក្រមសីលធម៌វិជ្ជាជីវៈបុគ្គលិកសិក្សា។

២. គុណវុឌ្ឍិ និងបទពិសោធន៍របស់បុគ្គលិកសិក្សា÷

ក. គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានបុគ្គលិកសិក្សាប្រកបដោយគុណវុឌ្ឍិ និងបទពិសោធន៍សមស្របទៅនឹង បេសកកម្ម កម្មវិធីសិក្សា និងបរិបទរបស់គ្រឹះស្ថានឧត្តមសិក្សា ⁄

ខ. បុគ្គលិកសិក្សា ត្រូវមានសញ្ញាបត្រខ្ពស់ជាងកម្រិតបណ្តុះបណ្តាលដែលខ្លួនបង្រៀន ចំពោះបុគ្គលិកសិក្សា ដែលមានសញ្ញាបត្រកម្រិតស្មើ ឬសមមូលនឹងកម្រិតបណ្តុះបណ្តាលត្រូវមានបទពិសោធន៍

បង្រៀន និង/ឬ បទពិសោធន៏ការងារពាក់ព័ន្ធនឹងគុណវឌ្ឍិ និងវិស័យ ដែលត្រូវបង្រៀនយ៉ាងតិច៣ឆ្នាំ។ បុគ្គលិកសិក្សាដែលមានសញ្ញាបត្រស្មើនឹងកម្រិតបណ្តុះបណ្តាល ដែលខ្លួនបង្រៀនហើយគ្មានបទពិសោធន៍ ៣ឆ្នាំអាចធ្វើជាគ្រូជំនួយ ។ ចំពោះអ្នកដែលមានចំណេះដឹងអនុវត្តជាក់ស្តែង និងបទពិសោធន៏ច្រើនឆ្នាំលើមុខវិជ្ជាណាមួយច្បាស់លាស់ប៉ុន្តែពុំមានសញ្ញាបត្រអាចធ្វើជាគ្រូជំនួយបាន ។

៣. លក្ខខណ្ឌការងារ និងគោលនយោបាយក្នុងការតម្លើងឋានៈ ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានលក្ខខណ្ឌការងារ កិច្ចសន្យាការងារ និងគោលការណ៏ច្បាស់លាស់ ក្នុងការតម្លើងឋានៈ ប្រាក់ឈ្នួល បៀវត្សរ៍ និងលាភការផ្សេងៗ

ខ. ប្រាក់ឈ្នួល និងលាភការផ្សេងៗដែលផ្តល់អោយបុគ្គលិកសិក្សា ត្រូវមានលក្ខណះសមស្រប និងផ្សាភ្ជាប់ទៅនឹងគោលបំណងរបស់គ្រឹះស្ថានឧត្តមសិក្សា

គ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគោលការណ៏ និងនីតិវិធីនៃការជ្រើសរើសបុគ្គលិកសិក្សា នីតិវិធីនៃការវាយតម្លៃ និងនីតិវិធីនៃការតម្លើងឋានៈបុគ្គលិកសិក្សាច្បាស់លាស់ ។

៤. ឯករាជ្យភាពក្នុងកិច្ចការសិក្សាធិការ ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តល់សេរីភាពច្បាស់លាស់ដល់បុគ្គលិកសិក្សាក្នុងការបង្រៀន ការស្រាវជ្រាវ និង ការបោះពុម្ពស្នាដៃនៃការស្រាវជ្រាវរបស់ខ្លួនក្នុងក្របខ័ណ្ឌវិជ្ជាជីវៈ

ខ. បុគ្គលិកសិក្សា ត្រូវមានសេរីភាពក្នុងការបញ្ចេញមតិលើកម្មវិធីសិក្សានិងទិដ្ឋភាពផ្សេងៗនៃគោលនយោបាយ របស់គ្រឹះស្ថានឧត្តមសិក្សាដែលទាក់ទងនឹងការទទួលខុសត្រូវ និងកម្រិតជំនាញ ។

៥. ការអភិវឌ្ឍសមត្ថភាពធនធានបុគ្គលិកសិក្សា ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តល់ឱកាសដល់បុគ្គលិកសិក្សាក្នុងការបន្តការសិក្សានិងចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗ ដើម្បីអភិវឌ្ឍជំនាញ និងបង្កើនចំណេះដឹង

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានកម្មវិធីអភិវឌ្ឍន៍បុគ្គលិកសិក្សា ដើម្បីពង្រឹងសមត្ថភាព និងបង្កើនចំណេះដឹង ។

៦. ភាពគ្រប់គ្រាន់នៃធនធានបុគ្គលិកសិក្សា ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានធនធានបុគ្គលិកសិក្សាគ្រប់គ្រាន់ស្របនឹងបេសកកម្មនៃកម្មវិធីសិក្សាដែលផ្តល់ដោយគ្រឹះស្ថានឧត្តមសិក្សា។ ផលធៀបរវាងបុគ្គលិកសិក្សា និងនិស្សិតនៅក្នុងកំរិតបណ្តុះបណ្តាលនីមួយៗ (បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត) គឺ១:៣០ ។ ប៉ុន្តែគ្រឹះស្ថានឧត្តមសិក្សាដែលបណ្តុះបណ្តាលវិស័យសុខាភិបាលត្រូវអនុលោមទៅតាមគោលការណ៍របស់ក្រសួងសុខាភិបាល

ខ. បុគ្គលិកសិក្សាម្នាក់មិនអាចបង្រៀនលើសពីពមុខវិជ្ជាក្នុងមួយឆមាសបានឡើយ ហើយមុខវិជ្ជាទាំងនោះត្រូវស្របទៅនឹងគុណវុឌ្ឍិ និងបទពិសោធន៍ការងាររបស់ខ្លួន ។ ម៉ោងបង្រៀនអតិបរមារបស់គ្រូបង្រៀននៅឧត្តមសិក្សាគឺមិនត្រូវលើសពី២៤ម៉ោងក្នុងមួយសប្តាហ៍

គ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានបុគ្គលិកសិក្សាពេញម៉ោងយ៉ាងតិច ២៥ភាគរយនៃចំនួនបុគ្គលិកសិក្សាសរុប ។ បុគ្គលិកសិក្សាពេញម៉ោងនៃគ្រឹះស្ថានឧត្តមសិក្សាមួយ ឬ បុគ្គលិកពេញម៉ោងនៃអង្គភាពមួយមិនអាចជាបុគ្គលិកសិក្សាពេញម៉ោងនៃគ្រឹះស្ថានឧត្តមសិក្សាមួយផ្សេងទៀតបានទេ

ឃ. គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានមធ្យោបាយប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការជ្រើសរើស និងរក្សាបុគ្គលិកសិក្សា ដែលមានគុណវុឌ្ឍិ និងសមត្ថភាពជំនាញចាំបាច់ ។

## ស្តង់ដារទី៥ ៖ និស្សិត និង សេវាសម្រាប់និស្សិត

និស្សិត និងសេវាសម្រាប់និស្សិតគាំទ្រដល់ការធានាបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា។ សេវាសម្រាប់និស្សិត រួមចំណែកដល់ការអភិវឌ្ឍចំណេះដឹង សមត្ថភាព និងជំនាញរបស់និស្សិត ដែលបានចុះឈ្មោះចូលរៀន និងបានរៀនចប់នៅគ្រឹះស្ថានឧត្តមសិក្សាឱ្យទទួលបានសញ្ញាបត្រប្រកបដោយជោគជ័យ។ ដើម្បីសម្រេចបានស្តង់ដារនេះ គ្រឹះស្ថានឧត្តមសិក្សា ត្រូវបំពេញសូចនាករដូចខាងក្រោម ÷

**សូចនាករ**

១. លក្ខខណ្ឌសម្រាប់ការចុះឈ្មោះចូលរៀន ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវលក្ខខណ្ឌនៃការចុះឈ្មោះចូលរៀន និងគោលនយោបាយដទៃទៀតដែលសមស្របនឹងបេសកកម្ម គោលដៅកម្មវិធីសិក្សា និងធនធានរបស់គ្រឹះស្ថាន

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះចូលសិក្សារបស់និស្សិតក្នុងជំនាញកម្រិតឧត្តមសិក្សា និងកម្រិតក្រោយឧត្តមសិក្សា។ លក្ខណៈវិនិច្ឆ័យទាំងនេះរួមបញ្ចូលទាំងពិន្ទុដែលកំណត់ ថាជាប់ក្នុងពេលសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។ ចំពោះគ្រឹះស្ថានឧត្តមសិក្សាដែលបណ្តុះបណ្តាលវិស័យ សុខាភិបាល ត្រូវបន្ថែមលក្ខខណ្ឌសម្រាប់ចូលរៀនស្របតាមស្មារតីអនុក្រឹត្យលេខ ២១អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ។

២. គ្រឹះស្ថានឧត្តមសិក្សាត្រូវថែងពីតម្រូវការចាំបាច់សម្រាប់កម្រិតសញ្ញាបត្រនីមួយៗ និងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

៣. ការកំណត់តម្លៃសិក្សា ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវកំណត់តម្លៃសិក្សាច្បាស់លាស់ ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគោលនយោបាយស្តីពីការសងថ្លៃសិក្សាក្នុងករណីដូចជា: (១) គ្រឹះស្ថានឧត្តម សិក្សាមិនបានបំពេញក្រេឌីតតាមការកំណត់ (២) គ្រឹះស្ថានឧត្តមសិក្សាបិទទ្វារ ឬក្ស័យធន ហើយត្រូវផ្សព្វផ្សាយគោលនយោបាយនេះជាសាធារណៈ។

៤. ដំណើរការផ្តល់អាហារូបករណ៍ ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានដំណើរការប្រកបដោយតម្លាភាព និងច្បាស់លាស់ក្នុងការផ្តល់អាហាររូបករណ៍

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្សព្វផ្សាយបញ្ជីឈ្មោះនិស្សិតដែលទទួលបានអាហារូបករណ៍ជាសាធារណៈ

គ. អាហារូបកណ៏សម្រាប់និស្សិតមានប្រភេទដូចខាងក្រោម ÷

- សម្រាប់និស្សិតពូកែ ឬ និស្សិតឆ្នើម
- សម្រាប់និស្សិតដែលមានសមត្ថភាពតែមិនអាចរ៉ាប់រងចំណាយក្នុងការបន្តការសិក្សា
- សម្រាប់និស្សិតដែលសិក្សាលើមុខជំនាញដែលរាជរដ្ឋាភិបាលកំណត់ថាជាមុខជំនាញអាទិភាព ឬមុខជំនាញចាំបាច់សម្រាប់សង្គម និង
- អាហារូបករណ៍ផ្សេងទៀតស្របតាមគោលនយោបាយរបស់ថ្នាក់ដឹកនាំ។

ឃ. ក្នុងការផ្តល់អាហារូបករណ៍ដល់និស្សិតត្រូវយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ ភូមិសាស្ត្រ និងជនជាតិភាគតិចក្នុងព្រះរាជាណាចក្រកម្ពុជា។

៥. ការផ្តល់សេវាកម្មរបស់គ្រឹះស្ថានឧត្តមសិក្សាចំពោះនិស្សិត ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តល់ប្រឹក្សាអំពីការសិក្សាដល់និស្សិត អំពីការបំពេញតម្រូវការចាំបាច់ក្នុងការទទួលបានសញ្ញាបត្រគ្រប់កម្រិត និងការជ្រើសរើសជំនាញស្របតាមតំរូវការទីផ្សារ។

ខ. គ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្តល់សេវាប្រកបដោយប្រសិទ្ធភាពដល់និស្សិត ។ សេវាកម្មទាំងនេះ អាចជាការស្នាក់នៅ សេវាម្ហូបអាហារ សេវាសង្គ្រោះបឋម សន្តិសុខ និងសកម្មភាពនានាបន្ថែមដទៃទៀត

គ. គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានបណ្ណាគារដែលគាំទ្រដល់កម្មវិធីសិក្សាស្របនឹងបេសកកម្មរបស់គ្រឹះស្ថាន

ឃ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគោលនយោបាយស្តីពី សិទ្ធិ និងការទទួលខុសត្រូវរបស់និស្សិតច្បាស់លាស់ និងត្រូវផ្សព្វផ្សាយ និងអនុវត្តប្រកបដោយយុត្តិធម៌

ង. គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តល់ការគាំទ្រ និងផ្តល់ឱកាសសម្រាប់និស្សិតក្នុងការចូលរួមក្នុងការងារមួយចំនួន ដូចជាសមាគមនិស្សិត សមាគមន៍អតីតនិស្សិត ហាត្ថការ និងការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំព្រមទាំងសកម្មភាពសិក្សាផ្សេងៗ ។

៦. ការផ្តល់សេវាសហគមន៍ ÷

គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តល់ឱកាស និងជំរុញអោយនិស្សិតចូលរួមក្នុងការផ្តល់សេវាសហគមន៍ និងសកម្មភាពការងារសង្គមផ្សេងៗ ។

# ស្តង់ដារទី៦ ៖ សេវាសិក្សា

សេវាសិក្សា ដូចជាបណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ បន្ទប់អនុវត្តន៍ ស្ថានីយ៍ពិសោធន៍ អ៊ីនធឺណេត សៀវភៅសិក្សា ឯកសារសិក្សាស្រាវជ្រាវ ។ល។ គាំទ្រដល់ការបង្រៀន ការសិក្សា និងការស្រាវជ្រាវរបស់និស្សិត និង បុគ្គលិកសិក្សាស្របនឹងបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា ។ សេវាសិក្សាត្រូវមានគ្រប់គ្រាន់ស្របតាមកម្រិតសញ្ញាបត្រ និងជំនាញ ដែលផ្តល់ដោយគ្រឹះស្ថានឧត្តមសិក្សា និងគាំទ្រដល់ការអភិវឌ្ឍវប្បធម៌ បច្ចេកវិទ្យា និងចំណេះដឹងរបស់និស្សិត ។ ធនធាន សិក្សាត្រូវមានគុណភាពល្អ និងមានភាពទាន់សម័យសម្រាប់ការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។ ដើម្បីសម្រេចបានស្តង់ដារនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវបំពេញសូចនាករដូចខាងក្រោម ÷

**សូចនាករ**

១. ភាពគ្រប់គ្រាន់នៃសេវាសិក្សាដែលប្រកបដោយគុណភាព និងទាន់សម័យ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានបន្ទប់ពិសោធន៍ ស្ថានីយ៍ពិសោធន៍ បន្ទប់អនុវត្តកុំព្យូទ័រ បន្ទប់ស្តាប់ភាសា និងសេវាសិក្សាផ្សេងៗគ្រប់គ្រាន់ស្របតាមតម្រូវការនៃកម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សា

ខ. បណ្ណាល័យត្រូវផ្សារភ្ជាប់ជាមួយកម្មវិធីសិក្សា និងសេចក្តីត្រូវការផ្សេងៗរបស់និស្សិត និងបុគ្គលិកសិក្សា ។ ឯកសារយោង ឯកសារស្រាវជ្រាវ និងឯកសារផ្សេងៗទៀតត្រូវមានចំនួនគ្រប់គ្រាន់ស្របតាមតម្រូវការ នៃកម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សា

គ. សៀវភៅ ឬ ឯកសារចងក្រងនៃមុខវិជ្ជាបង្រៀននីមួយៗ ត្រូវមានតម្កល់ក្នុងបណ្ណាល័យយ៉ាងតិចចំនួនប្រាំ (៥) ច្បាប់ ។ សៀវភៅ និងឯកសារពិគ្រោះ ឬ ឯកសារយោង ដែលយកមកប្រើប្រាស់ក្នុងមុខវិជ្ជានីមួយៗនៃកម្មវិធីសិក្សាត្រូវមានតម្កល់ក្នុងបណ្ណាល័យយ៉ាងតិចពីរ (២) ច្បាប់ក្នុងមួយចំណងជើង ។

ឃ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានសម្ភារបរិក្ខា ដូចជា LCDs, OHPs, CDs, DVDs និង សំភារៈផ្សេងៗ សម្រាប់បុគ្គលិកសិក្សាប្រើប្រាស់ក្នុងការបង្រៀន

ង. ត្រូវមានម៉ាស៊ីនថតចំលងក្នុងបណ្ណាល័យសម្រាប់បុគ្គលិកសិក្សា និង និស្សិតប្រើប្រាស់

ច. បណ្ណាល័យរបស់គ្រឹះស្ថានឧត្តមសិក្សាគួរធ្វើសហប្រតិបត្តិការជាមួយ បណ្ណាល័យផ្សេងៗទាំងក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ ។

២. ការគ្រប់គ្រងបណ្ណាល័យ ÷

ក. បណ្ណាល័យត្រូវមានអ្នកគ្រប់គ្រងដែលមានសញ្ញាបត្រទាបបំផុត ត្រឹមបរិញ្ញាបត្រ និងមានការបណ្តុះបណ្តាល ផ្នែកបណ្ណាល័យ និង ត្រូវមានបុគ្គលិកជំនួយការ ឬបណ្ណារក្សមួយចំនួនតាមការចាំបាច់

ខ. អ្នកគ្រប់គ្រងបណ្ណាល័យ និងបណ្ណារក្សមានតួនាទីទទួលខុសត្រូវកិច្ច ការគ្រប់គ្រងបណ្ណាល័យ ថែរក្សាគុណភាពសៀវភៅ និងឯកសារ ផ្សេងៗ ហើយត្រូវមានភារកិច្ចសម្របសម្រួលរវាងបណ្ណាល័យ និង គ្រឹះស្ថានឧត្តមសិក្សា បុគ្គលិកសិក្សា និស្សិត និងផ្នែកពាក់ព័ន្ធផ្សេងៗ

គ. អ្នកគ្រប់គ្រងបណ្ណាល័យត្រូវចូលរួមយ៉ាងសកម្មជាមួយបុគ្គលិក សិក្សាក្នុងការងារអភិវឌ្ឍន៍កម្មវិធីសិក្សា និងចូលរួមក្នុងសកម្មភាព ស្រាវជ្រាវនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា

ឃ. បណ្ណាល័យត្រូវមានគោលនយោបាយជាលាយល័ក្ខអក្សរ ដូចជា គោលការណ៍ប្រតិបត្តិ និងបទបញ្ជាផ្ទៃក្នុង ស្តីពីការខ្ចីសៀវភៅ និង ឯកសារផ្សេងៗ

ង. សៀវភៅសិក្សា និងឯកសារចងក្រងផ្សេងៗត្រូវរៀបចំជាកាតាឡុក ឬប្រព័ន្ធបច្ចេកវិទ្យា និងរៀបចំតាមប្រព័ន្ធគ្រប់គ្រងមួយច្បាស់ លាស់ ។

៣. សេវាបណ្ណាល័យ ÷

ក. បណ្ណាល័យត្រូវបើកទ្វារផ្តល់សេវាសម្រាប់ការចូលអាន និងការ សិក្សាស្រាវជ្រាវដែលមានរយៈពេលយ៉ាងតិចស្មើនឹងចំនួនម៉ោង សិក្សាប្រចាំថ្ងៃ

ខ. បណ្ណាល័យត្រូវផ្តល់កម្មវិធីបណ្តុះបណ្តាល ឬ ធ្វើបទបង្ហាញស្តីពីការ ប្រើប្រាស់បណ្ណាល័យ និងការប្រើប្រាស់ធនធានព័ត៌មានផ្សេងៗដល់ និស្សិត និងបុគ្គលិកសិក្សា ។

៤. ការគាំទ្រខាងហិរញ្ញវត្ថុ ៖

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់សេវាសិក្សា។ ផែនការថវិកានេះ ត្រូវស្របនឹងលទ្ធភាពថវិកា គោលនយោបាយសារពើពន្ធ និងនីតិវិធីរបស់គ្រឹះស្ថានឧត្តមសិក្សា

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវវិភាជថវិកាសម្រាប់អភិវឌ្ឍសេវាសិក្សា។

៥. ធនធានគាំទ្រសកម្មភាពបង្រៀន សកម្មភាពសិក្សា និងការស្រាវជ្រាវ ៖

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានសេវាសិក្សា ដើម្បីគាំទ្រដល់ការបង្រៀន និងការសិក្សា ព្រមទាំងគាំទ្រដល់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងបុគ្គលិកសិក្សា

ខ. បុគ្គលិកសិក្សាទាំងពេញម៉ោង និងមិនពេញម៉ោងត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់កុំព្យូទ័រដែលមានភ្ជាប់ បណ្តាញអ៊ីនធឺណេត និងម៉ាស៊ីនបោះពុម្ព ដើម្បីរៀបចំឯកសារបង្រៀន ការសិក្សាស្រាវជ្រាវ និងសកម្មភាពសិក្សាចំបាច់ផ្សេងៗ

គ. បន្ទប់ពិសោធន៍ ស្ថានីយ៍ពិសោធន៍ បន្ទប់អនុវត្តកុំព្យូទ័រ ឬបន្ទប់ស្តាប់ភាសារបស់គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានសម្ភាររូបវ័ន្តស្របនឹងកម្មវិធីសិក្សានិងមុខជំនាញ និងត្រូវមានមន្ត្រីគ្រប់គ្រងដែលមានបទពិសោធន៍។

៦. សេវាកុំព្យូទ័រ និងអ៊ីនធឺណេត ៖

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមាន Hardwares និង Softwares ស្របតាមតម្រូវការនៃកម្មវិធីសិក្សា និងជំនាញ។ Hardwares និង Softwares ត្រូវមានការអភិវឌ្ឍស្របតាមការវិវត្តបច្ចេកវិទ្យាថ្មី

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តល់ឱ្យនិស្សិតដែលសិក្សាក្នុងផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងព័ត៌មានវិទ្យាទទួលបានឱកាសក្នុងការប្រើប្រាស់កុំព្យូទ័រ និងសេវាផ្សេងៗស្របតាមតម្រូវការនៃកម្មវិធីសិក្សានិងជំនាញ

គ. និស្សិតដែលសិក្សាជំនាញផ្សេងក្រៅពីផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងព័ត៌មានវិទ្យា គ្រឹះស្ថានឧត្តមសិក្សាត្រូវ ផ្តល់សេវាកុំព្យូទ័រ និងអ៊ីនធឺណេតសមស្របតាមតម្រូវការ។

# ស្តង់ដារទី៧ ៖ ទីតាំងសម្ភាររូបវ័ន្ត

គ្រឹះស្ថានឧត្តមសិក្សាត្រូវមានសម្ភាររូបវ័ន្តសម្ភារបរិក្ខារសម្រាប់បំរើឱ្យការបង្រៀន និងសម្ភារបរិក្ខារចាំបាច់មួយ ចំនួនគ្រប់គ្រាន់ និងត្រូវរៀបចំនិងគ្រប់គ្រងឱ្យបានត្រឹមត្រូវ ដើម្បីសម្រេចបេសកកម្មរបស់គ្រឹះស្ថាន។ គ្រឹះស្ថានឧត្តមសិក្សា ត្រូវបង្កើតផែនការគ្រប់គ្រងសម្ភាររូបវ័ន្ត ដើម្បីធានាដល់ការលើកកម្ពស់គុណភាព និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចបានស្តង់ដារនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវបំពេញសូចនាករដូចខាងក្រោម ÷

**សូចនាករ**

១. ការរៀបចំផែនការ ការគ្រប់គ្រង និងការថែទាំសម្ភាររូបវ័ន្ត ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំផែនការគ្រប់គ្រងសម្ភាររូបវ័ន្តដោយឈរលើតម្រូវការពេលបច្ចុប្បន្ន និងអនាគត។ ផែនការគ្រប់គ្រងសម្ភាររូបវ័ន្តនេះត្រូវមានការកែលំអ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានផែនការអភិវឌ្ឍសម្ភាររូបវ័ន្ត និងផែនការជួសជុលកែលំអសម្ភាររូបវ័ន្ត ដោយផ្សារភ្ជាប់ទៅនឹងផែនការកៀងគរធនធាន ឬវិភាជដើមទុន និងហិរញ្ញវត្ថុសម្រាប់ដំណើរការគ្រឹះស្ថាន

គ. ការផ្លាស់ប្តូរសម្ភារបរិក្ខារត្រូវកំណត់ពេលវេលា ធ្វើគម្រោងថវិកា និងទិញឱ្យបានច្បាស់លាស់

ឃ. គ្រឹះស្ថានឧត្តមសិក្សាត្រូវធ្វើសារពើភណ្ឌ និងត្រួតពិនិត្យសម្ភាររូបវ័ន្តអោយបានត្រឹមត្រូវ និងជាប្រចាំ

ង. គ្រឹះស្ថានឧត្តមសិក្សាត្រូវមាន ឬ ត្រៀមទីតាំងផ្ទៃដី អគារ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់ធានាបំពេញតម្រូវការតាមកំណើននិស្សិត

ច. ករណីទីតាំងអគារជួលត្រូវមានរយៈពេលជួលយ៉ាងតិច៥ឆ្នាំគិតចាប់ពីថ្ងៃទទួលបានអាជ្ញាប័ណ្ណពីក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាល

ឆ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានប្លង់អគារ ដោយដាក់តាំងបង្ហាញ ដើម្បីសម្រួលដល់ការទំនាក់ទំនងផ្សេងៗ ។

២. ភាពគ្រប់គ្រាន់នៃសម្ភាររូបវ័ន្តដើម្បីគាំទ្របេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានមូលដ្ឋានសម្ភាររូបវ័ន្តគ្រប់គ្រាន់ ទាំងគុណភាព និងបរិមាណ ដើម្បីឆ្លើយតបទៅនឹងបេសកកម្មរបស់គ្រឹះស្ថាន។ សម្ភាររូបវ័ន្តទាំងនេះ រួមមាន អាគារសិក្សា ថ្នាក់រៀនគ្រប់ប្រភេទ សាលប្រជុំ បន្ទប់បុគ្គលិកសិក្សា ការិយាល័យ បន្ទប់អនាម័យ ទីធ្លាសម្រាប់ចតយានជំនិះ និងសម្ភារបំពាក់ផ្សេងៗ

ខ. គ្រឹះស្ថានឧត្តមសិក្សា ត្រូវស្ថិតនៅលើទីតាំងមួយប្រកបដោយបរិស្ថានសិក្សាល្អ និងត្រូវមានទីលានសម្រាប់កីឡា និងទីលានសម្រាប់សកម្មភាពផ្សេងៗ

គ. គ្រឹះស្ថានឧត្តមសិក្សា ត្រូវបំពាក់សម្ភារទូរគមនាគមន៍សម្រាប់ការប្រាស្រ័យទាក់ទងចាំបាច់នានាប្រកបដោយប្រសិទ្ធភាព។

៣. បញ្ហាសុខភាព សុវត្ថិភាព និងសន្តិសុខ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវយកចិត្តទុកដាក់លើបញ្ហាសុខភាព សុវត្ថិភាព និងសន្តិសុខក្នុងបរិវេណគ្រឹះស្ថាន

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានរចនាសម្ព័ន្ធសំណង់ប្រកបដោយសុវត្ថិភាព និងសន្តិសុខល្អ ហើយបង្កលក្ខណៈងាយស្រួលដល់និស្សិត និងនិស្សិតពិការភាព

គ. ករណីគ្រឹះស្ថានឧត្តមសិក្សាមានផ្តល់អន្តេវាសិកដ្ឋាន គ្រឹះស្ថានត្រូវរៀបចំអោយមានបរិយាកាសល្អសម្រាប់ និស្សិតស្នាក់នៅ និងសិក្សាប្រកបដោយសុខុមាលភាព និងសុវត្ថិភាព ហើយត្រូវមានមន្ត្រីទទួលខុសត្រូវ

ឃ. ករណីគ្រឹះស្ថានឧត្តមសិក្សាមានអាហារដ្ឋាន គ្រឹះស្ថានត្រូវយកចិត្តទុកដាក់លើបញ្ហាអនាម័យ និងសុខុមាលភាពអ្នកទទួលទាន ។

# ស្តង់ដារទី៨ : គម្រោងផែនការ និងការគ្រប់គ្រងថវិកា

ការរៀបចំផែនការហិរញ្ញវត្ថុ និងការបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ អាចធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ហិរញ្ញវត្ថុរបស់គ្រឹះស្ថានឧត្តមសិក្សា និងជាមូលដ្ឋានគ្រឹះសម្រាប់ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ ។ ភាពគ្រប់គ្រាន់នៃធនធាន ហិរញ្ញវត្ថុ អាចកំណត់បានតាមការវាយតម្លៃដោយផ្អែកលើបេសកកម្ម ស្ថានភាព វិសាលភាព និងភាពដោយឡែកពីគ្នានៃការ បណ្តុះបណ្តាល សេវាផ្សេងៗ ចំនួននិស្សិត និងប្រភេទនិស្សិតដែលបណ្តុះបណ្តាល ។ ដើម្បីសម្រេចបានស្តង់ដារនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវបំពេញសូចនាករដូចខាងក្រោម ÷

**សូចនាករ**

១. ភាពគ្រប់គ្រាន់នៃប្រភពធនធានហិរញ្ញវត្ថុ ÷

ក. គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានប្រភពធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីធានានូវគុណភាពនៃការបណ្តុះបណ្តាល និងនិរន្តរភាពនៃសេវាកម្ម និងកម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សា

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានថវិកាតម្កល់នៅធនាគារសម្រាប់បំរើដល់ដំណើរការរបស់ខ្លួន ។

២. ការធ្វើផែនការហិរញ្ញវត្ថុ និងការលើកផែនការថវិកា ÷

ក. គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុមួយច្បាស់លាស់

ខ. គ្រឹះស្ថានឧត្តមសិក្សាត្រូវធ្វើផែនការហិរញ្ញវត្ថុដោយផ្សារភ្ជាប់ទៅនឹងបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា

ឃ. គម្រោងថវិកាប្រចាំឆ្នាំ ការព្យាករណ៍រយៈពេលវែង និងគម្រោងប្រាក់ទុនរយៈពេលវែងនិងខ្លីត្រូវឆ្លុះបញ្ចាំងពីការវាយតម្លៃជាក់ស្តែងនៃធនធានដែលមាន និងតម្រូវការចំណាយសម្រាប់ការងារសិក្សាជាអាទិភាព

ង. តំណាងមហាវិទ្យាល័យ និងផ្នែកពាក់ព័ន្ធផ្សេងៗនៃគ្រឹះស្ថានឧត្តមសិក្សាត្រូវមានឱកាសចូលរួមក្នុងការបង្កើតគម្រោងថវិកា និងរៀបចំផែនការហិរញ្ញវត្ថុ ។

៣. ការធ្វើសវនកម្ម ៖

គ្រឹះស្ថានឧត្តមសិក្សាត្រូវធ្វើសវនកម្មប្រចាំឆ្នាំយ៉ាងទៀងទាត់តាមនីតិវិធី ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ អាជ្ញាធរសវនកម្មជាតិ ។

៤. ប្រសិទ្ធភាព នៃការប្រើប្រាស់ហិរញ្ញវត្ថុ ៖

ក. ហិរញ្ញវត្ថុរបស់គ្រឹះស្ថានឧត្តមសិក្សាត្រូវគ្រប់គ្រង ចាត់ចែង និង ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និង ចំគោលដៅដើម្បីធានា អោយការបណ្តុះបណ្តាលប្រព្រឹត្តទៅបានល្អ និងមានគុណភាព

ខ. បុគ្គលិកទទួលខុសត្រូវលើហិរញ្ញវត្ថុត្រូវមានបទពិសោធន៍ និង សញ្ញាបត្រជំនាញព្រមទាំងមានការយល់ដឹង ច្បាស់លាស់ពីគោល បំណងនៃការបណ្តុះបណ្តាលរបស់គ្រឹះស្ថានឧត្តមសិក្សា ។

៥. របាយការណ៍ហិរញ្ញវត្ថុ ៖

ក. របាយការណ៍ហិរញ្ញវត្ថុត្រូវគ្របដណ្តប់លើប្រតិបត្តិការទាំងមូល របស់គ្រឹះស្ថានឧត្តមសិក្សាដោយរាប់បញ្ចូល ទាំងថវិកាចំណូល ដូចជា ប្រាក់បានមកពីការបង់ថ្លៃសិក្សារបស់និស្សិត សកម្មភាពស្វែងរក មូលនិធិផ្សេងៗ ប្រាក់ចំណាយផ្សេងៗ និងរបាយការណ៍លំអិតនៃការ ងារលទ្ធកម្ម ។

ខ. គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងគ្រឹះស្ថានឧត្តមសិក្សាដែលជា គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រសម្រាប់ អភិវឌ្ឍគ្រឹះស្ថានជារៀងរាល់ឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ទៅក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមការ កំណត់

គ. ចំពោះគ្រឹះស្ថានឧត្តមសិក្សាឯកជនត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍគ្រឹះស្ថានជារៀងរាល់ឆ្នាំ និងរបាយការណ៍ហិរញ្ញ វត្ថុប្រចាំឆ្នាំទៅក្រុមប្រឹក្សាភិបាល តាមការការកំណត់របស់ក្រុម ប្រឹក្សាភិបាល ។

# ស្តង់ដារទី៩ : ការផ្សព្វផ្សាយព័ត៌មាន

គ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយជាសាធារណៈ តាមមធ្យោបាយផ្សេងៗដែលអាចធ្វើបាន ដូចជាតាមរយៈព្រឹត្តិប័ត្រ ទស្សនាវដ្ដី សៀវភៅផ្សព្វផ្សាយ និងគេហទំព័រ ។ល។ អំពីព័ត៌មានដែលពាក់ព័ន្ធនឹង ការអភិវឌ្ឍរបស់ខ្លួន។ ការផ្សព្វផ្សាយនេះ ជាផ្នែកមួយដ៏សំខាន់សម្រាប់ការយល់ដឹងពីសង្គម និស្សិត និយោជិត និងមាតា បិតានិស្សិត និងអ្នកពាក់ព័ន្ធទាំងក្នុងស្រុក និងអន្តរជាតិ។ ដើម្បីសម្រេចបាននូវលទ្ធផលខាងលើ គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្សព្វផ្សាយនូវរាល់ព័ត៌មានពាក់ព័ន្ធនឹងគ្រឹះស្ថានឧត្តមសិក្សាផ្ទាល់មួយចំនួនដូចខាងក្រោម ÷

១. បេសកកម្ម និងការរំពឹងទុករបស់និស្សិត
២. អភិបាលកិច្ចរបស់គ្រឹះស្ថានឧត្តមសិក្សា ដូចជារចនាសម្ព័ន្ធ ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមប្រឹក្សា ឬគណៈកម្មការនានា
៣. ព័ត៌មានទាក់ទងនឹងថ្លៃសិក្សា និងសេវាផ្សេងៗរបស់គ្រឹះស្ថានឧត្តមសិក្សា
៤. ព័ត៌មានទាក់ទងនឹងការផ្តល់អាហារូបករណ៍ដល់និស្សិត
៥. ការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំនៃគ្រឹះស្ថានឧត្តមសិក្សា
៦. លក្ខខណ្ឌនៃការជ្រើសរើស និងចំនួននិស្សិតដែលត្រូវជ្រើសរើសឱ្យចូលសិក្សាតាមមហាវិទ្យាល័យនិងជំនាញ
៧. គោលការណ៍ស្តីពីតម្រូវការចាំបាច់សម្រាប់កម្រិតសញ្ញាប័ត្រនីមួយៗ
៨. ឯកសារ និងព័ត៌មានផ្សេងៗទាក់ទងនឹងកម្មវិធីសិក្សា គោលនយោបាយនានា និងបទបញ្ជាផ្សេងៗ
៩. របាយការណ៍ប្រចាំឆ្នាំដែលបង្ហាញអំពីសកម្មភាពនានារបស់គ្រឹះស្ថានឧត្តមសិក្សា
១០. ឯកសារដែលទាក់ទងនឹងកម្មវិធីសិក្សា និងការចូលរួមរបស់គ្រឹះស្ថានឧត្តមសិក្សាក្នុងការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា
១១. លទ្ធផលនៃការទទួលស្គាល់គុណភាពអប់រំ

១២. ផែនការយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សាក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការបណ្តុះបណ្តាលរបស់គ្រឹះស្ថានឧត្តមសិក្សា និង

១៣. ព័ត៌មានចាំបាច់មួយចំនួនទៀត ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៤.-**

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក.) អគ្គលេខាធិការដ្ឋាន គ.ទ.ក. និង គ្រឹះស្ថានឧត្តមសិក្សាត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩

**ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សមាជិក គ.ទ.ក
- ឯកសារ-កាលប្បវត្តិ

# Minimum Standards for Accreditation of Higher Education Institutions

1. Mission
2. Governing Structure, Management and Planning
3. Academic Program
4. Academic Staff
5. Student and Student Services
6. Learning Services
7. Physical Plants
8. Financial Plan and Management
9. Dissemination of Information

2010

# Contents


| Titles | Page |
|---|---|
| Introduction ............................................ | 01 |
| Standard 1: Mission ....................................... | 03 |
| Standard 2: Governing structure, management and planning ................................ | 04 |
| Standard 3: Academic program ......................... | 09 |
| Standard 4: Academic staff .............................. | 13 |
| Standard 5: Student and student services........... | 16 |
| Standard 6: Learning services ......................... | 19 |
| Standard 7: Physical plants ............................. | 23 |
| Standard 8: Financial plan and management ....... | 25 |
| Standard 9: Dissemination of information .......... | 27 |

# DECISION
# ON
# MINIMUM STANDARDS FOR ACCREDITATION OF HIGHER EDUCATION INSTITUTIONS

CHAIRMAN OF ACCREDITATION COMMITTEE OF CAMBODIA

- seen the Constitution of the Kingdom of Cambodia
- seen the Royal Krom 02/NS/94, 20 July 1994, on the promulgation of laws on the organization and the functioning of the Council of Ministers
- seen the Royal Kret NS/RKT/0908/1055, 25 September 2008, on the nomination of Royal Government of the Kingdom of Cambodia
- seen the Royal Kret NS/RKT/0303/129, 31 March 2003, on the accreditation of higher education
